# سُورَةُ العَادِيَاتِ

# ស៊ូរ៉ោះទី ១០០

# អាល់-អាឌីយ៉ាត់

# سُورَةُ العَادِيَاتِ
# ស៊ូរ៉ោះត៍ ១០០ អាល់-អាឌីយ៉ាត់

"អាល់-អាឌីយ៉ាត់" ប្រែថា "អាជានេយ្យសឹក" មាន ១១ អាយ៉ាស់ ។

ស៊ូរ៉ោះត៍ទី ១៤ យោលតាមលេខរៀងដែលអល់ឡោះហ្ទ៍ﷻដាក់ចុះមក ។ អល់ឡោះហ្ទ៍ﷻបានដាក់ស៊ូរ៉ោះត៍នេះចុះមកនៅឯម៉ាក់កាស់ ។

## មគ្គផល - ប្រសិទ្ធភាព

١- ابْنُ بَابَوَيْهِ: بِإِسْنَادِهِ، عَنْ سُلَيْمَانَ بْنِ خَالِدٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلَامُ)، قَالَ: «مَنْ قَرَأَ سُورَةَ الْعَادِيَاتِ وَ أَدْمَنَ قِرَاءَتَهَا بَعَثَهُ اللَّهُ عَزَّ وَ جَلَّ مَعَ أَمِيرِ الْمُؤْمِنِينَ (عَلَيْهِ السَّلَامُ) يَوْمَ الْقِيَامَةِ خَاصَّةً، وَ كَانَ فِي حَجْرِهِ وَ رُفَقَائِهِ». (ثواب الأعمال الْجُزْء: ١ صَفْحَة : ١٢٥ ، البرهان في تفسير القرآن الْجُزْء : ٥ صَفْحَة : ٧٣١ حَدِيث ٩٩ /١١٨٣٦)**

1. អ៊ិបនូ បាបាវៃហ្ទ៍[មានប្រសាសន៍]យោលតាមបណ្ដាញព័ត៌មានលោក តមកពី ស៊ូឡៃម៉ាន ប៊ិន ខ៉ូលីដ តមកពី អាប៊ូ អាប់ឌុលឡោះហ្ទ៍ﷺដែលមានវចនៈថា៖ "អ្នកណាសូត្រស៊ូរ៉ោះត៍ [១០០] អាល់-អាឌីយ៉ាត់ជាទម្លាប់អល់ឡោះហ្ទ៍ﷻនឹងឲ្យអ្នកនោះរស់ឡើងវិញ ជាមួយអាមីរុល-មុមីនីនﷺថ្ងៃជំនុំជម្រះ អាមីរុល-មុមីនីនﷺនឹងការពារអ្នកនោះ ជាមិត្តរបស់អ្នកនោះ ។" (ثواب الأعمال: 125)

***

٢- وَ قَالَ الصَّادِقُ (عَلَيْهِ السَّلَامُ): «مَنْ قَرَأَهَا لِلْخَائِفِ أَمِنَ مِنَ الْخَوْفِ، وَ قِرَاءَتُهَا لِلْجَائِعِ يُسَكِّنُ جَوْعَهُ، وَ الْعَطْشَانِ يُسَكِّنُ عَطَشَهُ، فَإِذَا قَرَأَهَا وَ أَدْمَنَ قِرَاءَتَهَا الْمَدْيُونُ أَدَّى اللَّهُ عَنْهُ دَيْنَهُ بِإِذْنِ اللَّهِ تَعَالَى». (خواص القرآن: ١٥«مخطوط». البرهان في تفسير القرآن الْجُزْء : ٥ صَفْحَة : ٧٣١ حَدِيث ٩٩ /١١٨٣٩)**

2. អាល់-ស្វ៉ាឌិក្កﷺមានវចនៈថា៖ "អ្នកណាសូត្រស៊ូរ៉ោះត៍នេះព្រោះខ្លាច អ្នកនោះនឹងបាត់ភ័យខ្លាច ។ បើសូត្រស៊ូរ៉ោះត៍នេះព្រោះឃ្លាន វានឹងកម្ចាត់អាការឃ្លាន ។ បើសូត្រស៊ូរ៉ោះត៍នេះព្រោះស្រេកទឹក វានឹងកម្ចាត់អាការស្រេកទឹក ។ បើតែងតែសូត្រស៊ូរ៉ោះត៍នេះព្រោះចំពាក់បំណុល គេនឹងដោះបំណុលនោះ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ទ៍ تَعَالَى ។" (خواص القرآن: 15 «مخطوط»)

***

٣- فِي مَجْمَعِ الْبَيَانِ أُبَيُّ بْنُ كَعْبٍ عَنِ النَّبِيِّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ قَالَ: مَنْ قَرَأَهَا أُعْطِيَ مِنَ اَلْأَجْرِ عَشْرَ حَسَنَاتٍ، بِعَدَدِ مَنْ بَاتَ بِالْمُزْدَلِفَةِ وَ شَهِدَ جَمْعاً. (تفسير نور الثقلين ج٥ ص٦٥١)

3. នៅក្នុង[សាត្រា]ម៉ាជ្ម៉ាក់ អាល់-បាយ៉ាន អ៊ូបៃ ប៊ិន កាអាប់មានប្រសាសន៍ថារ៉ស៊ូលុលឡោះហ្ទ៍ﷺ មានព្រះវចនៈថា៖ "អ្នកណាសូត្រស៊ូរ៉ោះត៍នេះ អ្នកនោះនឹងបានរង្វាន់ស្មើនឹងចំនួនមនុស្សដែលមកកាន់អាល់-មុស្ដាលីហ្វាស់គុណដប់ ដែលបានជុំគ្នានៅទីនោះ ។" (تفسير نور الثقلين វគ្គ ១០០ ហ្វាឌីស្ស២)

***

*4– وَ مِنْ (خَوَاصِّ الْقُرْآنِ): رُوِيَ عَنِ النَّبِيِّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)، أَنَّهُ قَالَ: «مَنْ قَرَأَ هَذِهِ السُّورَةَ أُعْطِيَ مِنَ الْأَجْرِ كَمَنْ قَرَأَ الْقُرْآنَ،

*4. [ដកស្រង់]មកពី[សាត្រា]ខ៊ំវ៉ាស្ស៊ អាល់-គួរអានថារ៉ស៊ូលុលឡោះហ្ ﷺមានព្រះវចនៈថា៖ "អ្នកណាសូត្រស៊ូរ៉ោះត៍នេះ អ្នកនោះបានរង្វាន់ដូចបានសូត្រគួរអានមួយចប់ ។

وَ مَنْ أَدْمَنَ قِرَاءَتَهَا وَ عَلَيْهِ دَيْنٌ أَعَانَهُ اللَّهُ عَلَى قَضَائِهِ سَرِيعاً، كَائِناً مَا كَانَ». (خَوَاصِّ الْقُرْآنِ ، البرهان في تفسير القرآن اَلْجُزْء : ٥ صَفْحَة : ٧٣١ حَدِيث ٩٩ /١١٨٣٧)**

អ្នកដែលជំពាក់គេច្រើន សូត្រស៊ូរ៉ោះត៍នេះជាទម្លាប់ជួយឲ្យរួចពីជំពាក់ទេ ។ អល់ឡោះហ្ عَزَّ وَجَلَّនឹងជួយអ្នកនោះឲ្យឆាប់រួចពីបំណុល ។ អ្នកនោះនឹងដូចដើមវិញ (ពោលគឺគ្មានបំណុល) ។" (البرهان في تفسير القرآن)

***

*5– وَ قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ): «مَنْ صَلَّى بِهَا الْعِشَاءَ الْآخِرَةَ عَدَلَ ثَوَابُهَا نِصْفَ الْقُرْآنِ،

*5. រ៉ស៊ូលុលឡោះហ្ ﷺមានព្រះវចនៈថា៖ "អ្នកណាស្ម៊ឡាត់ អ៊ីស្សាអ៊ ជាមួយស៊ូរ៉ោះត៍នេះ អ្នកនោះបានរង្វាន់ស្មើនឹងពាក់កណ្តាលគួរអាន[ដោយស៊ូរ៉ោះត៍នេះ] ។

وَ مَنْ أَدْمَنَ قِرَاءَتَهَا وَ عَلَيْهِ دَيْنٌ أَعَانَهُ اللَّهُ تَعَالَى عَلَى قَضَائِهِ سَرِيعاً». (البرهان في تفسير القرآن اَلْجُزْء : ٥ صَفْحَة : ٧٣١ حَدِيث ٩٩ /١١٨٣٨)**

អ្នកដែលជាប់បំណុលច្រើន បើអ្នកនោះសូត្រស៊ូរ៉ោះត៍នេះជាទម្លាប់ អល់ឡោះហ្ عَزَّ وَجَلَّនឹងជួយអ្នកនោះឲ្យឆាប់សងគេរួច ។" (البرهان في تفسير القرآن)
--៦៨៤, ១៥៤, ៦៧៤

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ
ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

| | |
|---|---|
| ១. [អញស្បថ]នឹងអាជានេយ្យសឹកដង្ហក់ | وَٱلۡعَٰدِيَٰتِ ضَبۡحٗا ١ |
| ២. នឹងការបង្កើតផ្កាភ្លើងដោយប៉ះទង្គិច | فَٱلۡمُورِيَٰتِ قَدۡحٗا ٢ |
| ៣. នឹងបណ្តាអ្នកវាយលុកនាពេលព្រលឹម | فَٱلۡمُغِيرَٰتِ صُبۡحٗا ٣ |
| ៤. ដែលធ្វើឲ្យហុយធូលីក្នុងការវាយលុកនោះ | فَأَثَرۡنَ بِهِۦ نَقۡعٗا ٤ |
| ៥. ដែលលុកលុយចូលកណ្តាលប្រជុំជន ក្នុងការវាយលុកនោះ ។ | فَوَسَطۡنَ بِهِۦ جَمۡعًا ٥ |

| | |
|---|---|
| إِنَّ ٱلْإِنسَٰنَ لِرَبِّهِۦ لَكَنُودٌ ٦ | ៦. មនុស្ស[ដែលគ្មានការចេះដឹង]អកតញ្ញូ ចំពោះព្រះម្ចាស់ខ្លួន |
| وَإِنَّهُۥ عَلَىٰ ذَٰلِكَ لَشَهِيدٌ ٧ | ៧. ខ្លួនគេផ្ទាល់ជាសាក្សីនៃរឿងនោះ |
| وَإِنَّهُۥ لِحُبِّ ٱلْخَيْرِ لَشَدِيدٌ ٨ | ៨. ការពិតគេស្រឡាញ់ប្រការល្អខ្លាំងណាស់ ។ |
| ۞أَفَلَا يَعْلَمُ إِذَا بُعْثِرَ مَا فِى ٱلْقُبُورِ ٩ | ៩. គេមិនដឹងទេឬ ពេលអ្វីដែលនៅក្នុងផ្នូរត្រូវងើបឡើង |
| وَحُصِّلَ مَا فِى ٱلصُّدُورِ ١٠ | ១០.អ្វីដែលមាននៅក្នុងទ្រូងត្រូវបើកឲ្យឃើញ ? |
| إِنَّ رَبَّهُم بِهِمْ يَوْمَئِذٍ لَّخَبِيرٌۢ ١١ | ១១.ការពិត ថ្ងៃនោះ ព្រះម្ចាស់ពួកគេទ្រង់ញាណពួកគេច្បាស់ ។ |

## អធិប្បាយអាយ៉ាស់ ១-១១

١– عَلِيُّ بْنُ إِبْرَاهِيمَ، قَالَ: حَدَّثَنَا جَعْفَرُ بْنُ أَحْمَدَ، عَنْ عُبَيْدِ اللَّهِ بْنِ مُوسَى، قَالَ: حَدَّثَنَا الْحَسَنُ بْنُ عَلِيِّ بْنِ أَبِي حَمْزَةَ، عَنْ أَبِيهِ، عَنْ أَبِي بَصِيرٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِهِ تَعَالَى: ''وَ الْعادِياتِ ضَبْحاً * فَالْمُورِياتِ قَدْحاً''، قَالَ: «هَذِهِ السُّورَةُ نَزَلَتْ فِي أَهْلِ وَادِي الْيَابِسِ».

1. អុលី ប៊ិន អ៊ីប៉រហ៊ីម មានប្រសាសន៍[នៅក្នុងតាហ្វ៉ស៊ីរគុម្មី]ថា យ៉ាក់ហ្វារ ប៊ិន អាស់ម៉ាដ់ បាននិយាយប្រាប់យើងតមកពី អ៊ូបៃឌុលឡោះហ៍ ប៊ិន មូសា តមកពី អាល់-ហាសាន់ ប៊ិន អុលី ប៊ិន អាប៊ូ ហាំស្សាស់ តមកពីឪពុកលោក តមកពី អាប៊ូ បាស្សៀរ តមកពី អាប៊ូ អាប់ឌុលឡោះហ៍ عليه والسلام ។ ព្រះអង្គ عليه والسلام មានវចនៈអំពីព្រះបន្ទូលអល់ឡោះហ៍ تعالى *[១០០:១] [អញស្បថ]នឹងអាជានេយ្យសឹកដង្ហក់ [១០០:២] នឹងការបង្កើតផ្កាភ្លើងដោយប៉ះទង្គិច* ថា៖ "ស៊ូរ៉ោះត្ទ័នេះត្រូវបើកឲ្យដឹងអំពីអ្នកស្រុកច្រក អាល់-យ៉ាប៊ីស ។"

قَالَ: قُلْتُ: وَ مَا كَانَ حَالُهُمْ وَ قِصَّتُهُمْ؟ قَالَ: «إِنَّ أَهْلَ وَادِي الْيَابِسِ اجْتَمَعُوا اثْنَيْ عَشَرَ أَلْفَ فَارِسٍ، وَ تَعَاقَدُوا وَ تَعَاهَدُوا وَ تَوَافَقُوا عَلَى أَنْ لاَ يَتَخَلَّفَ رَجُلٌ عَنْ رَجُلٍ، وَ لاَ يَخْذُلَ أَحَدٌ أَحَداً، وَ لاَ يَفِرَّ رَجُلٌ عَنْ صَاحِبِهِ حَتَّى يَمُوتُوا كُلُّهُمْ عَلَى حِلْفٍ وَاحِدٍ، وَ يَقْتُلُوا رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) وَ عَلِيّاً (عَلَيْهِ السَّلاَمُ)، فَنَزَلَ جَبْرَئِيلُ (عَلَيْهِ السَّلاَمُ) عَلَى رَسُولِ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)، وَ أَخْبَرَهُ بِقِصَّتِهِمْ وَ مَا تَعَاقَدُوا عَلَيْهِ وَ تَوَافَقُوا، وَ أَمَرَهُ أَنْ يَبْعَثَ أَبَا بَكْرٍ إِلَيْهِمْ فِي أَرْبَعَةِ آلاَفِ فَارِسٍ مِنَ الْمُهَاجِرِينَ وَ الْأَنْصَارِ،

លោកបានថាខ្ញុំបានទូលថា៖ "តើស្ថានភាពនិងរឿងរ៉ាវពួកគេយ៉ាងណាទៅ ?" ព្រះអង្គ عليه والسلام មានវចនៈថា៖ "ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស បានប្រមូលទ័ពសេះចំនួនដប់ពីរពាន់នាក់ ។ ពួកគេបានសន្យាគ្នា បានចូលរួម បានយល់ព្រមស្របមតិគ្នាថាមិនឲ្យអ្នកណាម្នាក់ប្រឆាំងអ្នកណាម្នាក់ទេ មិនឲ្យអ្នកណាម្នាក់បោះបង់ចោលអ្នកណាម្នាក់ទេ មិនឲ្យអ្នកណាម្នាក់រត់ចោលអ្នកណាម្នាក់ទេ លុះត្រាតែពួកគេទាំងអស់គ្នាស្លាប់ក្នុងសម្បថតែមួយ គឺស្បថថាសម្លាប់រ៉សូលុលឡោះហ៍ ﷺ និងអុលី عليه والسلام ។ យ៊ីបរ៉អ៊ីល عليه السلام បានចុះមកប្រាប់រ៉សូលុលឡោះហ៍ ﷺ ឲ្យជ្រាបអំពីរឿងពួកគេនិងការរួមគំនិតគ្នា ។ អល់ឡោះហ៍ عزّوجلّ បានដាក់ព្រះរាជបញ្ជាឲ្យរ៉សូលុលឡោះហ៍ ﷺ ចាត់បញ្ជូន អាប៊ូ បាការ ទៅជួបពួកគេជាមួយទ័ពសេះបួន

ពាន់នាក់ដែលមានពួកមូហាជីរីននិងពួកអាន់ស្វារ ។"

فَصَعِدَ رَسُولُ اللّٰهِ (صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ) الْمِنْبَرَ، فَحَمِدَ اللّٰهَ وَ أَثْنَى عَلَيْهِ، ثُمَّ قَالَ:يَا مَعْشَرَ الْمُهَاجِرِينَ وَ الْأَنْصَارِ، إِنَّ جَبْرَئِيلَ قَدْ أَخْبَرَنِي أَنَّ أَهْلَ وَادِي الْيَابِسِ اثْنَا عَشَرَ أَلْفَ فَارِسٍ،قَدِ اسْتَعَدُّوا وَ تَعَاهَدُوا وَ تَعَاقَدُوا عَلَى أَنْ لاَ يَغْدِرَ رَجُلٌ مِنْهُمْ بِصَاحِبِهِ وَ لاَ يَفِرَّ عَنْهُ، وَ لاَ يَخْذُلَهُ حَتَّى يَقْتُلُونِي وَ أَخِي عَلِيَّ بْنَ أَبِي طَالِبٍ، [وَ قَدْ] أَمَرَنِي أَنْ أُسَيِّرَ إِلَيْهِمْ أَبَا بَكْرٍ فِي أَرْبَعَةِ آلاَفِ فَارِسٍ، فَخُذُوا فِي مَسِيرِكُمْ، وَ اسْتَعِدُّوا لِعَدُوِّكُمْ، وَ انْهَضُوا إِلَيْهِمْ عَلَى اسْمِ اللّٰهِ وَ بَرَكَتِهِ يَوْمَ الْإِثْنَيْنِ إِنْ شَاءَ اللّٰهُ تَعَالَى.

រ៉ស៊ូលុលឡោះហ៍صَلَّى اللّٰهُ عَلَيْهِ وَآلِهِបានឡើងលើវេទិកា បានធ្វើសក្ការៈអល់ឡោះហ៍عَزَّ وَجَلَّ បានលើកតម្កើងព្រះអង្គعَزَّ وَجَلَّ ហើយមានព្រះវចនៈថា៖ "មូហាជីរីននិងអាន់ស្វារអើយ ។ យ៉ីបរ៉អ៊ីលعَلَيْهِ السَّلَامُបានប្រាប់ខ្ញុំصَلَّى اللّٰهُ عَلَيْهِ وَآلِهِថា ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស មានទ័ពសេះដប់ពីរពាន់នាក់ដែលត្រៀមខ្លួនស្រេចហើយ ដែលបានរួមគំនិតគ្នា បានសន្យាគ្នាថាពួកគេនឹងមិនក្បត់គ្នាទេ មិនរត់ចោលគ្នានិងមិនបោះបង់គ្នាចោលទេលុះត្រាតែបានសម្លាប់ខ្ញុំصَلَّى اللّٰهُ عَلَيْهِ وَآلِهِនិងប្អូនصَلَوَاتُ اللّٰهِ عَلَيْهِ وَالسَّلَامُ ខ្ញុំصَلَّى اللّٰهُ عَلَيْهِ وَآلِهِ អាលីصَلَوَاتُ اللّٰهِ عَلَيْهِ وَالسَّلَامُ ប៊ិន អាប៊ូ តក៏លិបرَضِيَ اللّٰهُ عَنْهُ ។ អល់ឡោះហ៍عَزَّ وَجَلَّបានឲ្យខ្ញុំصَلَّى اللّٰهُ عَلَيْهِ وَآلِهِចាត់បញ្ជូន អាប៊ូ បាការ ទៅប្រយុទ្ធនឹងពួកគេជាមួយទ័ពសេះបួនពាន់នាក់ ។ ដូច្នេះចូរអស់លោករៀបចំស្បៀងសម្រាប់ធ្វើដំណើរ ហើយត្រៀមខ្លួនប្រយុទ្ធនឹងសត្រូវរបស់អស់លោក ។ ចូរអស់លោកងើបឡើងច្បាំងពួកគេក្នុងព្រះនាមអល់ឡោះហ៍عَزَّ وَجَلَّនិងព្រះពរព្រះអង្គعَزَّ وَجَلَّក្នុងថ្ងៃចន្ទ បើព្រះអង្គتَعَالَىមានព្រះបំណង ។"

فَأَخَذَ الْمُسْلِمُونَ عُدَّتَهُمْ وَ تَهَيَّؤُوا، وَ أَمَرَ رَسُولُ اللّٰهِ (صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ) أَبَا بَكْرٍ بِأَمْرِهِ، وَ كَانَ فِيمَا أَمَرَهُ بِهِ أَنَّهُ إِذَا رَآهُمْ أَنْ يَعْرِضَ عَلَيْهِمُ الْإِسْلاَمَ، فَإِنْ بَايَعُوكَ وَ إِلاَّ وَاقِفْهُمْ، فَاقْتُلْ مُقَاتِلِيهِمْ، وَ اسْبِ ذَرَارِيَّهُمْ، وَ اسْتَبِحْ أَمْوَالَهُمْ، وَ خَرِّبْ ضِيَاعَهُمْ وَ دِيَارَهُمْ

ពួកមុស្លីមបានប្រុងប្រៀប ត្រៀមខ្លួនស្រេច រ៉ស៊ូលុលឡោះហ៍صَلَّى اللّٰهُ عَلَيْهِ وَآلِهِបានដាក់បញ្ជាលើ អាប៊ូ បាការ ដោយមានសេចក្តីបង្គាប់នានា ។ ព្រះអង្គصَلَّى اللّٰهُ عَلَيْهِ وَآلِهِបានដាក់ព្រះបញ្ជាអំពីរឿងនេះថា៖ "ពេលណាលោកជួបពួកគេ ពេលនោះចូរលោកប្រកាសអាល់-អ៊ីស្លាមឲ្យពួកគេជ្រាប ។ ដូច្នេះបើពួកគេព្រមស្តាប់បង្គាប់លោក (ជាការប្រសើរ) ឬពុំនោះទេចូរបញ្ឈប់ពួកគេ ។ ដូច្នេះចូរប្រយុទ្ធនឹងយុទ្ធជនពួកគេនិងចាប់ខ្លួនពួកគេ ចាប់ទ្រព្យពួកគេ កម្ទេចលំនៅដ្ឋានពួកគេ ។"

فَمَضَى أَبُو بَكْرٍ وَ مَعَهُ مِنَ الْمُهَاجِرِينَ وَ الْأَنْصَارِ فِي أَحْسَنِ عُدَّةٍ، وَ أَحْسَنِ هَيْئَةٍ،يَسِيرُ بِهِمْ سَيْراً رَفِيقاً حَتَّى انْتَهَوْا إِلَى أَهْلِ وَادِي الْيَابِسِ، فَلَمَّا نَظَرَ الْقَوْمُ نُزُولَ الْقَوْمِ عَلَيْهِمْ، وَ نَزَلَ أَبُو بَكْرٍ وَ أَصْحَابُهُ قَرِيباً مِنْهُمْ، خَرَجَ إِلَيْهِمْ مِنْ أَهْلِ وَادِي الْيَابِسِ مِائَتَا رَجُلٍ مُدَجَّجِينَ بِالسِّلاَحِ، فَلَمَّا صَادَفُوهُمْ قَالُوا لَهُمْ: مَنْ أَنْتُمْ؟ وَ مِنْ أَيْنَ أَقْبَلْتُمْ؟ وَ أَيْنَ تُرِيدُونَ؟ لِيَخْرُجْ إِلَيْنَا صَاحِبُكُمْ حَتَّى نُكَلِّمَهُ فَخَرَجَ إِلَيْهِمْ أَبُو بَكْرٍ فِي نَفَرٍ مِنْ أَصْحَابِهِ الْمُسْلِمِينَ، فَقَالَ لَهُمْ: أَنَا أَبُو بَكْرٍ صَاحِبُ رَسُولِ اللّٰهِ. قَالُوا: مَا أَقْدَمَكَ عَلَيْنَا؟ قَالَ: أَمَرَنِي رَسُولُ اللّٰهِ أَنْ أَعْرِضَ عَلَيْكُمُ الْإِسْلاَمَ، فَإِنْ تَدْخُلُوا فِيمَا دَخَلَ فِيهِ الْمُسْلِمُونَ، لَكُمْ مَا لَهُمْ، وَ عَلَيْكُمْ مَا عَلَيْهِمْ، وَ إِلاَّ فَالْحَرْبُ بَيْنَنَا وَ بَيْنَكُمْ

អាប៊ូ បាការ ក៏បានចេញទៅ ជាមួយពួកមូហាជីរីននិងពួកអាន់ស្វារ ដោយការរៀបចំយ៉ាងល្អនិងមានកម្លាំងកាយល្អ ។ គាត់ធ្វើដំណើរជាមួយពួកគេលុះទៅដល់ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស ។ ពេលពួកប្រជារាស្ត្រមើលឃើញពួកគេ ពួកគេបានលើកទ័ពមកកាន់ទីតាំង ។ អាប៊ូ បាការ និងបក្សពួកក៏បានបោះជំរំទ័ពនៅក្បែរពួកគេ ។ ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស មួយរយនាក់បានចេញមកជួបពួកគេ

ដោយប្រដាប់អាវុធច្រើន ។ ពួកប្រជារាស្ត្រនោះបានមកប្រឈមពួកគេ ហើយបានថា៖ "ពួកអ្នកជាអ្នកណា ? មកពីណា ? ចូរមកចរចាជាមួយយើង ។" អាប៊ូ បាការ បានចេញទៅជួបពួកគេជាមួយបក្សពួកមុស្លីមមួយចំនួន ។ គាត់បាននិយាយជាមួយពួកគេថា៖ "ខ្ញុំគឺ អាប៊ូ បាការ បក្សពួករបស់រ៉ស៊ូលុលឡោះហ្ ﷺ ។" ពួកគេបានថា៖ "ហេតុអ្វីលោកមករកយើង ?" អាប៊ូ បាការ បានថា៖ "រ៉ស៊ូលុលឡោះហ្ ﷺ បានបញ្ជាឲ្យខ្ញុំមកប្រកាសអាល់-អ៊ីស្លាមដល់អស់លោក ។ បើអស់លោកព្រមចូលមកកាន់អ្វីដែលពួកមុស្លីមកាន់នោះ អស់លោកនឹងបានអ្វីដែលពួកគេបាន អ្វីដែលជំទាស់អស់លោកនឹងជំទាស់ពួកគេដែរ ពុំនោះទេនឹងមានសង្គ្រាមរវាងយើងនិងអស់លោក ។

قَالُوا: وَ اللاَّتِ وَ الْعُزَّى، لَوْ لاَ رَحِمٌ مَاسَّةٌ وَ قَرَابَةٌ قَرِيبَةٌ لَقَتَلْنَاكَ وَ جَمِيعَ مَنْ مَعَكَ قِتْلَةً تَكُونُ حَدِيثاً لِمَنْ يَكُونُ بَعْدَكُمْ، فَارْجِعْ أَنْتَ وَ مَنْ مَعَكَ وَ ارْبَحُوا الْعَافِيَةَ، فَإِنَّا إِنَّمَا نُرِيدُ صَاحِبَكُمْ بِعَيْنِهِ، وَ أَخَاهُ عَلِيَّ بْنَ أَبِي طَالِبٍ.

ពួកគេបានថា៖ "សូមស្បថលើ អាល់-ឡាត់ និង អាល់-អ៊ុស្សា (រូបព្រះពីរ) បើពួកលោកមិនមែនជាសាច់ញាតិជិតទេយើងនឹងសម្លាប់អស់លោកនិងពួកដែលនៅជាមួយអស់លោក ឲ្យទៅជារឿងនិទានរបស់ជនជំនាន់ក្រោយ ។ ដូច្នេះអស់លោកត្រឡប់ទៅវិញទៅ លោកនិងពួកដែលជាគ្នារបស់លោក ទាន់មានសុខភាពល្អ ព្រោះយើងចង់បានតែម្ចាស់ ﷺ របស់អស់លោកនិងប្អូន ﷺ របស់គេ ﷺ អាលី ﷺ ប៊ិន អាប៊ូ ត៊ូលិប ﷺ ទេ

فَقَالَ أَبُو بَكْرٍ لِأَصْحَابِهِ: يَا قَوْمِ، الْقَوْمُ أَكْثَرُ مِنْكُمْ أَضْعَافاً، وَ أَعَدُّ مِنْكُمْ، وَ قَدْ نَأَتْ دَارُكُمْ عَنْ إِخْوَانِكُمْ مِنَ الْمُسْلِمِينَ، فَارْجِعُوا؛نُعْلِمْ رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) بِحَالِ الْقَوْمِ، فَقَالُوا لَهُ جَمِيعاً: خَالَفْتَ-يَا أَبَا بَكْرٍ- قَوْلَ رَسُولِ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) وَ مَا أَمَرَكَ بِهِ، فَاتَّقِ اللَّهَ وَ وَاقِعِ الْقَوْمَ، وَ لاَ تُخَالِفْ قَوْلَ رَسُولِ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) فَقَالَ: إِنِّي أَعْلَمُ مَا لاَ تَعْلَمُونَ، وَ الشَّاهِدُ يَرَى مَا لاَ يَرَى الْغَائِبُ، فَانْصَرَفَ وَ انْصَرَفَ النَّاسُ أَجْمَعُونَ، فَأُخْبِرَ النَّبِيُّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) بِمَقَالَةِ الْقَوْمِ، وَ مَا رَدَّ عَلَيْهِمْ أَبُو بَكْرٍ، فَقَالَ [رَسُولُ اللَّهِ] (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ): يَا أَبَا بَكْرٍ، خَالَفْتَ أَمْرِي، وَ لَمْ تَفْعَلْ مَا أَمَرْتُكَ بِهِ، وَ كُنْتَ لِي وَ اللَّهِ عَاصِياً فِيمَا أَمَرْتُكَ.

អាប៊ូ បាការ បានប្រាប់បក្សពួកថា៖ "ពួកគេមានគ្នាច្រើនជាងអស់លោក ប្រុងខ្លួនបានល្អជាងអស់លោក អស់លោកនៅឆ្ងាយពីផ្ទះនិងបងប្អូនមុស្លីមរបស់អស់លោក ។ ដូច្នេះយើងត្រឡប់ទៅវិញ ប្រាប់រ៉ស៊ូលុលឡោះហ្ ﷺ ឲ្យជ្រាបអំពីប្រជារាស្ត្រនេះ ។" ពួកគេបានប្រាប់គាត់ជាឯកច្ឆន្ទថា៖ "អាប៊ូ បាការ អឺយ លោកបានប្រឆាំងព្រះបន្ទូលរបស់រ៉ស៊ូលុលឡោះហ្ ﷺ និងអ្វីដែលព្រះអង្គ ﷺ ដាក់មកជាបញ្ជាលើលោក ។ ដូច្នេះចូរលោកខ្លាចអល់ឡោះហ្ ﷻ ចូរបញ្ឈប់ប្រជារាស្ត្រនេះ កុំប្រឆាំងរ៉ស៊ូលុលឡោះហ្ ﷺ ។" គាត់បានថា៖ "ខ្ញុំដឹងអ្វីដែលអស់លោកមិនដឹង អ្នកមានវត្តមានឃើញផ្ទាល់ភ្នែកនូវអ្វីដែលអ្នកអវត្តមានមិនបានឃើញទេ ។" គាត់បានចាកចេញ ទាំងអស់គ្នាក៏បានចាកចេញជាមួយគាត់ ។ ពួកគេបានទូលរ៉ស៊ូលុលឡោះហ្ ﷺ អំពីការសន្ទនាជាមួយប្រជារាស្ត្រនោះ និងអំពីអ្វីដែល អាប៊ូ បាការ បានឆ្លើយតបពួកគេ ។ រ៉ស៊ូលុលឡោះហ្ ﷺ មានព្រះវចនៈថា៖ "អាប៊ូ បាការ អឺយ លោកបានប្រឆាំងបញ្ជាខ្ញុំ ﷺ មិនបានធ្វើអ្វីដែលខ្ញុំ ﷺ បានបញ្ជាឲ្យលោកធ្វើទេ ។ សូមស្បថនឹងអល់ឡោះហ្ ﷻ លោកមិនធ្វើតាមបញ្ជាដែលខ្ញុំ ﷺ បានបញ្ជាឲ្យលោកធ្វើនោះទេ ។"

فَقَامَ النَّبِيُّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) حَتَّى صَعِدَ الْمِنْبَرَ، فَحَمِدَ اللَّهَ وَ أَثْنَى عَلَيْهِ، ثُمَّ قَالَ: يَا مَعْشَرَ الْمُسْلِمِينَ، إِنِّي أَمَرْتُ أَبَا بَكْرٍ أَنْ يَسِيرَ

إِلَى أَهْلِ وَادِي الْيَابِسِ، وَ أَنْ يَعْرِضَ عَلَيْهِمُ الْإِسْلاَمَ، وَ يَدْعُوَهُمْ إِلَى اللَّهِ، فَإِنْ أَجَابُوهُ وَ إِلاَّ وَاقَعَهُمْ، وَ إِنَّهُ سَارَ إِلَيْهِمْ، وَ خَرَجَ إِلَيْهِ مِنْهُمْ مِائَتَا رَجُلٍ، فَلَمَّا سَمِعَ كَلاَمَهُمْ وَ مَا اسْتَقْبَلُوهُ بِهِ انْتَفَخَ سَحْرُهُ، وَ دَخَلَهُ الرُّعْبُ مِنْهُمْ، وَ تَرَكَ قَوْلِي، وَ لَمْ يُطِعْ أَمْرِي، وَ إِنَّ جَبْرَئِيلَ (عَلَيْهِ السَّلاَمُ) جَاءَ مِنْ عِنْدِ اللَّهِ أَنْ أَبْعَثَ إِلَيْهِمْ عُمَرَ مَكَانَهُ فِي أَصْحَابِهِ فِي أَرْبَعَةِ آلاَفِ فَارِسٍ، فَسِرْ يَا عُمَرُ عَلَى اسْمِ اللَّهِ، وَ لاَ تَعْمَلْ مَا عَمِلَ أَبُو بَكْرٍ أَخُوكَ، فَإِنَّهُ قَدْ عَصَى اللَّهَ وَ عَصَانِي، وَ أَمَرَهُ بِمَا أَمَرَ بِهِ أَبَا بَكْرٍ.

ព្រះសាស្ដាﷺបានឡើងទៅលើវេទិកា ។ ព្រះអង្គﷺបានធ្វើសក្ការៈអល់ឡោះហ៍عَزَّ وَجَلَّ លើកតម្កើងព្រះអង្គعَزَّ وَجَلَّ ហើយមានព្រះវចនៈថា៖ "ក្រុមមុស្លីមអឺយ! ខ្ញុំﷺបានបញ្ជាឲ្យ អាប៊ូ បាការ ធ្វើដំណើរទៅជួបប្រជារាស្ត្រច្រក អាល់-យ៉ាប៊ីស ឲ្យប្រកាសអាល់-អ៊ីស្លាមចំពោះពួកគេ ឲ្យហៅពួកគេមករកអល់ឡោះហ៍عَزَّ وَجَلَّ ។ បើពួកគេឆ្លើយតបមកលោក[ជាការប្រសើ]) ពុំនោះទេឲ្យបញ្ឈប់ពួកគេ ។ លោកបានធ្វើដំណើរទៅរកពួកគេ ពួកគេមួយរយនាក់បានចេញមកជួបលោក ។ ពេលលោកបានឮសម្ដីពួកគេនិងអ្វីដែលពួកគេនឹងយកមកប្រឈមនឹងលោក លោកភ័យរន្ធត់ កំសាក លោកចាញ់ប្រៀបពួកគេ មិនអើពើបញ្ជាខ្ញុំﷺទេ មិនអនុវត្តិតាមបញ្ជាខ្ញុំﷺទេ ។ យ៉ីបរ៉អ៊ីលعليه السلامបានមកពីអល់ឡោះហ៍عَزَّ وَجَلَّថាខ្ញុំﷺគប្បីចាត់បញ្ជូន អ៊ូម៉ារ ទៅជាជំនួសលោក ជាមួយបក្សពួកទ័ពសេះរបស់លោកបួនពាន់នាក់ ។ ដូច្នេះ អ៊ូម៉ារ អឺយ ចូរលោកទៅចុះ ក្នុងព្រះនាមអល់ឡោះហ៍عَزَّ وَجَلَّ ចូរកុំយកតម្រាប់តាម អាប៊ូ បាការ អ្វីដែលបងប្អូនលោកបានធ្វើនោះឡើយ ព្រោះលោកមិនស្ដាប់ឱវាទអល់ឡោះហ៍عَزَّ وَجَلَّនិងឱវាទខ្ញុំﷺទេ ។ ដូច្នេះ ខ្ញុំﷺដាក់បញ្ជាលើលោកដូចខ្ញុំﷺបានដាក់បញ្ជាលើ អាប៊ូ បាការ ដែរ ។"

فَخَرَجَ عُمَرُ وَ الْمُهَاجِرِينَ وَ الْأَنْصَارَ الَّذِينَ كَانُوا مَعَ أَبِي بَكْرٍ يَقْصِدُ فِي سَيْرِهِ حَتَّى شَارَفَ الْقَوْمَ وَ كَانَ قَرِيباً مِنْهُمْ بِحَيْثُ يَرَاهُمْ وَ يَرَوْنَهُ، فَخَرَجَ إِلَيْهِمْ مِائَتَا رَجُلٍ، فَقَالُوا لَهُ وَ لِأَصْحَابِهِ مِثْلَ مَقَالَتِهِمْ لِأَبِي بَكْرٍ، فَانْصَرَفَ وَ انْصَرَفَ النَّاسُ مَعَهُ، وَ كَادَ أَنْ يَطِيرَ قَلْبُهُ مِمَّا رَأَى مِنْ عُدَّةِ الْقَوْمِ وَ جَمْعِهِمْ، وَ رَجَعَ يَهْرُبُ مِنْهُمْ، فَنَزَلَ جَبْرَئِيلُ (عَلَيْهِ السَّلاَمُ) فَأَخْبَرَ رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) بِمَا صَنَعَ عُمَرُ، وَ أَنَّهُ قَدِ انْصَرَفَ وَ انْصَرَفَ الْمُسْلِمُونَ مَعَهُ.

អ៊ូម៉ារ ក៏បានចាកចេញទៅជាមួយពួកមូហាយីរីននិងពួកអាន់ស្វារដែលបានទៅជាមួយ អាប៊ូ បាការ បានធ្វើដំណើរតាមផ្លូវតែមួយលុះបានទៅដល់ប្រជារាស្ត្រទាំងនោះ ដែលនៅជិតពួកគេ គាត់អាចមើលឃើញពួកគេ ពួកគេក៏អាចមើលឃើញគាត់ដែរ ។ មនុស្សមួយរយនាក់បានចេញមកជួបគាត់ បាននិយាយជាមួយគាត់និងបក្សពួកគាត់ដូចដែលពួកគេបានប្រាប់ អាប៊ូ បាការ នោះដែរ ។ ដូច្នេះ អ៊ូម៉ារ បានចាកចេញ ប្រជារាស្ត្រក៏បានចាកចេញជាមួយគាត់ ។ បេះដូងគាត់ស្ទើរតែចេញបាត់ពីខ្លួនគាត់ ពេលគាត់បានឃើញចំនួនពួកគេនិងការប្រដាប់អាវុធរបស់ពួកគេ ។ គាត់បានរត់គេចខ្លួនពីពួកគេ ។ យ៉ីបរ៉អ៊ីលعليه السلامបានចុះមកទូលរ៉ស៊ូលុលឡោះហ៍ﷺអំពីអ្វីដែលអ៊ូម៉ារបានធ្វើ ថាគាត់បានចាកចេញ ឯពួកមុស្លីមក៏បានចាកចេញជាមួយគាត់ ។

فَصَعِدَ النَّبِيُّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) الْمِنْبَرَ، فَحَمِدَ اللَّهَ وَ أَثْنَى عَلَيْهِ، وَ أَخْبَرَهُمْ بِمَا صَنَعَ عُمَرُ وَ مَا كَانَ مِنْهُ، وَ أَنَّهُ قَدْ انْصَرَفَ [وَ انْصَرَفَ] الْمُسْلِمُونَ مَعَهُ مُخَالِفاً لِأَمْرِي، عَاصِياً لِقَوْلِي، فَقَدِمَ عَلَيْهِ فَأَخْبَرَهُ بِمِثْلِ مَا أَخْبَرَ بِهِ صَاحِبَهُ، فَقَالَ: يَا عُمَرُ، عَصَيْتَ اللَّهَ فِي عَرْشِهِ وَ عَصَيْتَنِي، وَ خَالَفْتَ قَوْلِي، وَ عَمِلْتَ بِرَأْيِكَ،

ព្រះសាស្តាصَلَّى اللهُ عَلَيْهِ وَآلِهِបានឡើងទៅលើវេទិកា ។ ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِបានធ្វើសក្ការៈអល់ឡោះហ្ម៍عَزَّ وَجَلَّ បានលើកតម្កើងព្រះអង្គعَزَّ وَجَلَّ ហើយបានប្រាប់ពួកគេឲ្យដឹងអំពីអ្វីដែលអ៊ុម៉ារបានធ្វើ និងអ្វីដែលបានកើតឡើងពីនោះ ។ ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِមានព្រះវចនៈថា៖ "លោកបានចាកចេញ ពួកមុស្លីមក៏បានចាកចេញជាមួយលោក ប្រឆាំងបញ្ជាខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِ ប្រព្រឹត្តល្មើសបង្គាប់ខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِ ។ លោកបានទៅជួបពួកគេ ពួកគេបានប្រាប់លោកនូវអ្វីដែលពួកគេបានប្រាប់កនលោកហើយនោះដែរ ។" ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِមានព្រះវចនៈថា៖ "អ៊ុម៉ារអើយ! លោកមិនស្តាប់ព្រះឱវាទអល់ឡោះហ្ម៍عَزَّ وَجَلَّក្នុងព្រះរាជបល្ល័ង្កព្រះអង្គعَزَّ وَجَلَّទេ លោកមិនស្តាប់ឱវាទខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِទេ លោកបានប្រឆាំងសម្តីខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِ ហើយបានប្រព្រឹត្តតាមតែចិត្តឯង ។

أَلاَ قَبَّحَ اللَّهُ رَأْيَكَ، وَ إِنَّ جَبْرَئِيلَ (عَلَيْهِ السَّلاَمُ) قَدْ أَمَرَنِي أَنْ أَبْعَثَ عَلِيَّ بْنَ أَبِي طَالِبٍ (عَلَيْهِ السَّلاَمُ) فِي هَؤُلاَءِ الْمُسْلِمِينَ، وَ أَخْبَرَنِي أَنَّ اللَّهَ يَفْتَحُ عَلَيْهِ وَ عَلَى أَصْحَابِهِ، فَدَعَا عَلِيّاً (عَلَيْهِ السَّلاَمُ) وَ أَوْصَاهُ بِمَا أَوْصَى بِهِ أَبَا بَكْرٍ وَ عُمَرَ وَ أَصْحَابَهُ الْأَرْبَعَةَ آلاَفٍ، وَ أَخْبَرَهُ أَنَّ اللَّهَ سَيَفْتَحُ عَلَيْهِ وَ عَلَى أَصْحَابِهِ.

ការពិតមតិរបស់លោកជាមតិអាក្រក់[សម្រាប់]អល់ឡោះហ្ម៍عَزَّ وَجَلَّ ។ យ៉ីបរ៉អ៊ីលعَلَيْهِ السَّلَامُបាននាំព្រះបញ្ជាមកថាឲ្យខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِចាត់បញ្ជូន អាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ប៊ីន អាប៊ូ ត៏លិបرَضِيَ اللهُ عَنْهُ ទៅជាមួយមុស្លីមទាំងនោះ ហើយយ៉ីបរ៉អ៊ីលعَلَيْهِ السَّلَامُបានប្រាប់ខ្ញុំصَلَّى اللهُ عَلَيْهِ وَآلِهِថាអល់ឡោះហ្ម៍عَزَّ وَجَلَّនឹងធានាជ័យជំនះឲ្យអាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُនិងបក្សពួករបស់គេصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។" ដូច្នេះព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِបានហៅអាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមកជួប បានប្រាប់ឲ្យជ្រាបអ្វីដែលព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِប្រាប់ អាប៊ូ បាការ អ៊ុម៉ារ និងបក្សពួកពួកគាត់បួនពាន់នាក់នោះ ។ ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِបានប្រាប់ អាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ថាអល់ឡោះហ្ម៍عَزَّ وَجَلَّនឹងធានាជ័យជំនះឲ្យមកព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُនិងបក្សពួកព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។"

فَخَرَجَ عَلِيٌّ (عَلَيْهِ السَّلاَمُ) وَ مَعَهُ الْمُهَاجِرُونَ وَ الْأَنْصَارُ، فَسَارَ بِهِمْ سَيْراً غَيْرَ سَيْرِ أَبِي بَكْرٍ وَ عُمَرَ، وَ ذَلِكَ أَنَّهُ أَعْنَفَ بِهِمْ فِي السَّيْرِ حَتَّى خَافُوا أَنْ يَنْقَطِعُوا مِنَ التَّعَبِ وَ تَحْفَى دَوَابُّهُمْ، فَقَالَ لَهُمْ: لاَ تَخَافُوا، فَإِنَّ رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) قَدْ أَمَرَنِي بِأَمْرٍ، وَ أَخْبَرَنِي أَنَّ اللَّهَ سَيَفْتَحُ عَلَيَّ وَ عَلَيْكُمْ، فَأَبْشِرُوا فَإِنَّكُمْ عَلَى خَيْرٍ وَ إِلَى خَيْرٍ، فَطَابَتْ نُفُوسُهُمْ وَ قُلُوبُهُمْ، وَ سَارُوا عَلَى ذَلِكَ السَّيْرِ وَ التَّعَبِ، حَتَّى إِذَا كَانَ قَرِيباً مِنْهُمْ حَيْثُ يَرَوْنَهُ وَ يَرَاهُمْ، أَمَرَ أَصْحَابَهُ أَنْ يَنْزِلُوا،

អាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបានចេញទៅ ជាមួយពួកមូហាយ៉ីរីននិងពួកអាន់ស្វារ ។ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបានធ្វើដំណើរតាមផ្លូវមួយផ្សេងពីផ្លូវដែល អាប៊ូ បាការ និង អ៊ុម៉ារ បានដើរនោះ ហើយជាផ្លូវមួយពិបាកដើរ ។ ពិបាកដល់ថ្នាក់ពួកគេខ្លាចតែខានបំពេញបេសកកម្មនេះ ព្រោះនឿយហត់ពេក ឯយានជំនិះក៏អស់កម្លាំង ។ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបានប្រាប់ពួកគេថា៖ "អស់លោកកុំខ្លាច ព្រោះរ៉ស៊ូលុលឡោះហ្ម៍صَلَّى اللهُ عَلَيْهِ وَآلِهِបានដាក់បញ្ជាមួយលើខ្ញុំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ហើយបានប្រាប់ខ្ញុំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُថាអល់ឡោះហ្ម៍عَزَّ وَجَلَّនឹងធានាជ័យជំនះឲ្យយើងដោយដៃខ្ញុំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ សម្រាប់អស់លោក ។ ដូច្នេះចូរទទួលយកដំណឹងល្អចុះ ព្រោះអស់លោកស្ថិតនៅលើសេចក្តីល្អ និងឆ្ពោះទៅកាន់សេចក្តីល្អ ។" បេះដូងនិងចិត្តពួកគេបានធូរស្រាលប្រសើរឡើង ។ ពួកគេធ្វើដំណើរលុះបានទៅដល់ជិតពួកគេនោះ ។ ពួកគេអាចមើលព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُឃើញ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُអាចមើលឃើញពួកគេ ។ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានបញ្ជាឲ្យបក្សពួកព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបោះជំរំ ។

وَ سَمِعَ أَهْلُ وَادِي الْيَابِسِ بِمَقْدَمِ عَلِيِّ بْنِ أَبِي طَالِبٍ (عَلَيْهِ السَّلاَمُ) وَ أَصْحَابِهِ، فَخَرَجَ إِلَيْهِمْ مِنْهُمْ مِائَتَا رَجُلٍ شَاكِينَ فِي السِّلاَحِ، فَلَمَّا رَآهُمْ عَلِيٌّ (عَلَيْهِ السَّلاَمُ) خَرَجَ إِلَيْهِمْ فِي نَفَرٍ مِنْ أَصْحَابِهِ، فَقَالُوا لَهُمْ:مَنْ أَنْتُمْ؟ وَ مِنْ أَيْنَ أَقْبَلْتُمْ؟ وَ أَيْنَ تُرِيدُونَ؟ قَالَ: أَنَا عَلِيُّ بْنُ أَبِي

طَالِبٍ، ابْنُ عَمِّ رَسُولِ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) وَ أَخُوهُ، وَ رَسُولُهُ إِلَيْكُمْ، أَدْعُوكُمْ إِلَى شَهَادَةِ أَنْ لاَ إِلَهَ إِلاَّ اللَّهُ، وَ أَنَّ مُحَمَّداً رَسُولُ اللَّهِ، وَ لَكُمْ [إِنْ آمَنْتُمْ] مَا لِلْمُسْلِمِينَ وَ عَلَيْكُمْ مَا عَلَيْهِمْ مِنْ خَيْرٍ وَ شَرٍّ. فَقَالُوا لَهُ: إِيَّاكَ أَرَدْنَا، وَ أَنْتَ طَلِبَتُنَا، قَدْ سَمِعْنَا مَقَالَتَكَ وَ مَا عَرَضْتَ عَلَيْنَا، [هَذَا مَا لاَ يُوَافِقُنَا]، فَخُذْ حِذْرَكَ، وَ اسْتَعِدَّ لِلْحَرْبِ الْعَوَانِ، وَ اعْلَمْ أَنَّا قَاتِلُوكَ وَ قَاتِلُوا أَصْحَابِكَ، وَ الْمَوْعُودُ فِيمَا بَيْنَنَا وَ بَيْنَكَ غَداً ضَحْوَةً، وَ قَدْ أَعْذَرْنَا فِيمَا بَيْنَنَا وَ بَيْنَكَ.

ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស បានឮ អាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត្ហលិប رضي الله عنه និងបក្សពួកខិតចូលមកជិត ។ គ្នាពួកគេមួយរយនាក់ ប្រដាប់អាវុធយ៉ាងច្រើន បានចេញទៅជួបពួកគេ ។ ពេលអាលី صلوات الله عليه والسلام បានឃើញពួកគេ ព្រះអង្គ صلوات الله عليه والسلام បានចេញទៅជួបពួកគេជាមួយបក្សពួកមួយចំនួនរបស់ព្រះអង្គ صلوات الله عليه والسلام ។ ពួកគេបានសួរព្រះអង្គ صلوات الله عليه والسلام ថា៖ "អ្នក صلوات الله عليه والسلام ជាអ្នកណា ? មកពីណា ? អ្នក صلوات الله عليه والسلام ចង់បានអ្វី ?" ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ខ្ញុំ صلوات الله عليه والسلام អាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត្ហលិប رضي الله عنه ប្អូនជីតាមួយរបស់រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله ប្អូនរបស់ព្រះអង្គ صلى الله عليه وآله ហើយជាអ្នកនាំព្រះរាជសារព្រះអង្គ صلى الله عليه وآله មកឲ្យអស់លោក ។ ខ្ញុំ صلوات الله عليه والسلام មកទីនេះដើម្បីហៅអស់លោកមកប្ដេជ្ញាថា៖ "មិនមានព្រះផ្សេងពីអល់ឡោះហ៍ عز وجل ឡើយ ។ មូហាំម៉ាដ់ صلى الله عليه وآله ជាព្រះសាសនៈទូតរបស់ព្រះអង្គ عز وجل ។" បើអស់លោកព្រមប្រកាសជំនឿ អស់លោកនឹងបានអ្វីដែលពួកមុស្លីមបាន ប្រឆាំងអស់លោកអ្វីដែលប្រឆាំងពួកមុស្លីម ទាំងអាក្រក់ទាំងល្អ ។" ពួកគេបានប្រាប់ព្រះអង្គ صلوات الله عليه والسلام ថា៖ "លោក صلوات الله عليه والسلام គឺអ្នកដែលយើងចង់បាន លោក صلوات الله عليه والسلام មករកយើង ? យើងបានស្ដាប់លោក صلوات الله عليه والسلام និងអ្វីដែលលោក صلوات الله عليه والسلام បានប្រកាសប្រាប់យើងហើយ ។ រឿងនេះមិនស៊ីចិត្តយើងទេ ។ ដូច្នេះចូរលោក صلوات الله عليه والسلام ប្រយ័តខ្លួន ចូរត្រៀមខ្លួនប្រយុទ្ធ ។ ចូរដឹងថាខ្ញុំនឹងសម្លាប់លោក صلوات الله عليه والسلام និងបក្សពួកលោក صلوات الله عليه والسلام ។ ការប្រយុទ្ធនឹងចាប់ផ្ដើមថ្ងៃស្អែករវាងយើងនិងលោក صلوات الله عليه والسلام ។ យើងអធ្យាស្រ័យឲ្យគ្នា រវាងយើងនិងលោក صلوات الله عليه والسلام ។"

فَقَالَ [لَهُمْ] عَلِيٌّ (عَلَيْهِ السَّلاَمُ): وَيْلَكُمْ تُهَدِّدُونِّي بِكَثْرَتِكُمْ وَ جَمْعِكُمْ، فَأَنَا أَسْتَعِينُ بِاللَّهِ وَ مَلاَئِكَتِهِ وَ الْمُسْلِمِينَ عَلَيْكُمْ، وَ لاَ حَوْلَ وَ لاَ قُوَّةَ إِلاَّ بِاللَّهِ الْعَلِيِّ الْعَظِيمِ فَانْصَرَفُوا إِلَى مَرَاكِزِهِمْ، وَ انْصَرَفَ عَلِيٌّ (عَلَيْهِ السَّلاَمُ) إِلَى مَرْكَزِهِ، فَلَمَّا جَنَّ اللَّيْلُ أَمَرَ أَصْحَابَهُ أَنْ يُحْسِنُوا إِلَى دَوَابِّهِمْ وَ يُقْضِمُوا وَ يَحُسُّوا وَ يُسْرِجُوا، فَلَمَّا انْشَقَّ عَمُودُ الصُّبْحِ صَلَّى بِالنَّاسِ بِغَلَسٍ، ثُمَّ أَغَارَ عَلَيْهِمْ بِأَصْحَابِهِ، فَلَمْ يَعْلَمُوا حَتَّى وَطِئَتْهُمْ الْخَيْلُ، فَمَا أَدْرَكَ آخِرُ أَصْحَابِهِ حَتَّى قَتَلَ مُقَاتِلِيهِمْ، وَ سَبَى ذَرَارِيَّهُمْ، وَ اسْتَبَاحَ أَمْوَالَهُمْ، وَ خَرَّبَ دِيَارَهُمْ، وَ أَقْبَلَ بِالْأُسَارَى وَ الْأَمْوَالِ مَعَهُ،

អាលី صلوات الله عليه والسلام មានវចនៈថា៖ "អពមង្គលលើអស់លោក ។ អស់លោកយកគ្នាច្រើននិងសាមគ្គីភាពរបស់អស់លោកមកគំរាមខ្ញុំ صلوات الله عليه والسلام ។ អល់ឡោះហ៍ عز وجل គាំទ្រខ្ញុំ صلوات الله عليه والسلام អស់ទេវតានិងមុស្លីមប្រឆាំងអស់លោក ។ មិនមានឥទ្ធិពល ឬ មហិទ្ធឫទ្ធិទេ ក្រៅពីដោយសារអល់ឡោះហ៍ عز وجل ។" ពួកគេបានត្រឡប់ទៅកាន់ទីតាំងវិញ ឯអាលី صلوات الله عليه والسلام ក៏បានត្រឡប់ទៅកាន់ទីតាំងវិញដែរ ។ ពេលយប់ព្រះអង្គ صلوات الله عليه والسلام បានបញ្ជាឲ្យបក្សពួកព្រះអង្គ صلوات الله عليه والسلام ដោះបន្ទុកសត្វជំនិះ ឲ្យទឹកវា ដុសធូលីវា ចងកែបវា ។ ពេលថ្ងៃជិតរះព្រះអង្គ صلوات الله عليه والسلام បានស៊ូឡាត់ជាមួយប្រជារាស្ត្រ ហើយបានចូលប្រយុទ្ធជាមួយបក្សពួកព្រះអង្គ صلوات الله عليه والسلام ។ ពួកសត្រូវមិនបានដឹងជាមុនទេ ទាល់តែសេះពួកគេបានលុកលុយមកលើខ្លួន ។ កនក្រោយបង្អស់របស់ពួកគេមិនទាំងដឹងផងទេថាកនរបស់ខ្លួនត្រូវគេសម្លាប់ ។ ព្រះអង្គ صلوات الله عليه والسلام បានចាប់ខ្លួនប្រជារាស្ត្រពួកគេ ចាប់ទ្រព្យពួកគេ កម្ទេចលំនៅដ្ឋានពួកគេចោល ហើយបាននាំអ្នកទោសនិងទ្រព្យទៅជាមួយព្រះអង្គ صلوات الله عليه والسلام ។

وَ نَزَلَ جَبْرَئِيلُ (عَلَيْهِ السَّلاَمُ)، فَأَخْبَرَ رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) بِمَا فَتَحَ اللَّهُ عَلَى عَلِيٍّ (عَلَيْهِ السَّلاَمُ) وَ جَمَاعَةِ الْمُسْلِمِينَ،

فَصَعِدَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) الْمِنْبَرَ، فَحَمِدَ اللَّهَ وَ أَثْنَى عَلَيْهِ، وَ أَخْبَرَ النَّاسَ بِمَا فَتَحَ اللَّهُ عَلَى الْمُسْلِمِينَ، وَ أَعْلَمَهُمْ أَنَّهُ لَمْ يُقْتَلْ مِنْهُمْ إِلاَّ رَجُلاَنِ، فَنَزَلَ، وَ خَرَجَ يَسْتَقْبِلُ عَلِيّاً (عَلَيْهِ السَّلاَمُ) فِي جَمِيعِ أَهْلِ الْمَدِينَةِ مِنَ الْمُسْلِمِينَ حَتَّى لَقِيَهُ عَلَى ثَلاَثَةِ أَمْيَالٍ مِنَ الْمَدِينَةِ، فَلَمَّا رَآهُ عَلِيٌّ (عَلَيْهِ السَّلاَمُ) مُقْبِلاً نَزَلَ عَنْ دَابَّتِهِ، وَ نَزَلَ النَّبِيُّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) حَتَّى الْتَزَمَهُ، وَ قَبَّلَ مَا بَيْنَ عَيْنَيْهِ، فَنَزَلَ جَمَاعَةُ الْمُسْلِمِينَ إِلَى عَلِيٍّ (عَلَيْهِ السَّلاَمُ) حَيْثُ نَزَلَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)، فَأَقْبَلَ بِالْغَنِيمَةِ وَ الْأُسَارَى وَ مَا رَزَقَهُمُ اللَّهُ بِهِ مِنْ أَهْلِ وَادِي الْيَابِسِ».

យ៉ីបរ៉អ៊ីល عليه السلام បានចុះមកទូលរ៉ស៊ូលុលឡោះហ្ ﷺ អំពីជ័យជំនះដែលអល់ឡោះហ្ ﷻ បានផានាប្រទានឲ្យអ៊ុាលី صلوات الله عليه والسلام និងក្រុមមុស្លីម ។ រ៉ស៊ូលុលឡោះហ្ ﷺ បានឡើងទៅលើវេទិកា ។ ព្រះអង្គ ﷺ បានធ្វើសក្ការៈអល់ឡោះហ្ ﷻ បានលើកតម្កើងព្រះអង្គ ﷻ ហើយបានប្រាប់ប្រជារាស្ត្រឲ្យដឹងអំពីជ័យជំនះដែលអល់ឡោះហ្ ﷻ បានផានាប្រទានឲ្យពួកមុស្លីម ហើយព្រះអង្គ ﷺ បានឲ្យពួកគេដឹងថាពួកគេមិនមានអ្នកស្លាប់លើសពីពីរនាក់ទេ ។ ព្រះអង្គ ﷺ បានចេញទៅស្វាគមន៍អ៊ុាលី صلوات الله عليه والسلام ជាមួយអ្នកស្រុកម៉ាឌីណាស៊ូមុស្លីម បានជួបព្រះអង្គ صلوات الله عليه والسلام ឆ្ងាយពីម៉ាឌីណាស៊ូប្រមាណប្រាំគីឡូម៉ែត្រ ។ ពេលអ៊ុាលី صلوات الله عليه والسلام បានឃើញព្រះអង្គ ﷺ ព្រះអង្គ صلوات الله عليه والسلام បានចុះពីលើសេះ ។ ព្រះសាស្ដា ﷺ បានចុះមកឱបព្រះអង្គ صلوات الله عليه والسلام ហើយបានថើបព្រះអង្គ صلوات الله عليه والسلام ត្រង់ចន្លោះភ្នែក ។ ក្រុមមុស្លីមបានចុះពីជំនិះមករកអ៊ុាលី صلوات الله عليه والسلام ត្រង់កន្លែងដែលរ៉ស៊ូលុលឡោះហ្ ﷺ បានចុះពីជំនិះ ហើយបានបែរទៅរករបស់យកបានពីសត្រូវ ពួកអ្នកទោស និងជីវព្រឹត្តិដែលអល់ឡោះហ្ ﷻ បានផ្ដល់ឲ្យពួកគេ ពីពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស ។

ثُمَّ قَالَ جَعْفَرُ بْنُ مُحَمَّدٍ (عَلَيْهِمَا السَّلاَمُ): «مَا غَنِمَ الْمُسْلِمُونَ مِثْلَهَا قَطُّ إِلاَّ أَنْ يَكُونَ مِنْ خَيْبَرَ، فَإِنَّهَا مِثْلُ خَيْبَرَ، فَأَنْزَلَ اللَّهُ تَبَارَكَ وَ تَعَالَى فِي ذَلِكَ "وَ الْعادِياتِ ضَبْحاً" يَعْنِي بِالْعَادِيَاتِ الْخَيْلَ تَعْدُو بِالرِّجَالِ، وَ الضَّبْحُ: صَيْحَتُهَا فِي أَعِنَّتِهَا وَ لُجُمِهَا ''فَالْمُورِياتِ قَدْحاً * فَالْمُغِيراتِ صُبْحاً'' فَقَدْ أَخْبَرْتُكَ أَنَّهَا أَغَارَتْ عَلَيْهِمْ صُبْحاً».

បន្ទាប់មក យ៉ាក់ហ្វារ صلوات الله عليه والسلام ប៊ិន មូហ៊ាំម៉ាដ់ صلوات الله عليه والسلام មានវចនៈថា៖ "ពួកមុស្លីមមិនដែលបានទ្រព្យសង្គ្រាមដូចនេះទេ លើកលែងតែទ្រព្យសមរភូមិខៃយ៉បារ ព្រោះនោះដូចផលប្រយោជន៍ដែលបានពីខៃយ៉បារ ។ ដូច្នេះអល់ឡោះហ្ تبارك وتعالى បានបើកឲ្យដឹងអំពីរឿងនេះថា *[១០០:១] [អញស្បថ]នឹងអាជានេយ្យសឹកដង្ហក់* មានន័យថាសេះបោលជាមួយមនុស្ស ស្រែកតាមខ្សែបង្ហៀរ ហើយត្រូវគេទប់វា ។ *[១០០:២] នឹងការបង្កើតផ្កាភ្លើងដោយប៉ះទង្គិច [១០០:៣] នឹងបណ្ដាអ្នកវាយលុកនាពេលព្រលឹម ។* អល់ឡោះហ្ ﷻ ប្រាប់អស់លោកថាពួកគេបានវាយលុកពួកគេនៅពេលព្រលឹម ។"

[قُلْتُ] :قَوْلُهُ: فَأَثَرْنَ بِهِ نَقْعاً ؟ قَالَ: «يَعْنِي الْخَيْلَ، فَأَثَرْنَ بِالْوَادِي نَقْعاً فَوَسَطْنَ بِهِ جَمْعاً ». قُلْتُ: قَوْلُهُ: ''إِنَّ الْإِنْسانَ لِرَبِّهِ لَكَنُودٌ''؟ قَالَ: «لَكَفُورٌ». ''وَ إِنَّهُ عَلىٰ ذٰلِكَ لَشَهِيدٌ''؟ قَالَ: «يَعْنِيهِمَا جَمِيعاً، قَدْ شَهِدَا جَمِيعاً وَادِيَ الْيَابِسِ، وَ كَانَا لِحُبِّ الْحَيَاةِ حَرِيصَيْنِ».

ខ្ញុំបានសួរថា៖ "[មានន័យថាអ្វី] ព្រះបន្ទូលព្រះអង្គ ﷻ *[១០០:៤] ដែលធ្វើឲ្យហុយធូលីក្នុងការវាយលុកនោះ?"* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "មានន័យថាសេះធ្វើឲ្យហុយធូលីនៅក្នុងច្រកនោះ ។ *[១០០:៥] ដែលលុកលុយចូលកណ្ដាលប្រជុំជនក្នុងការវាយលុកនោះ ។"* ខ្ញុំបានសួរថា៖ "[មានន័យថាអ្វី] ព្រះបន្ទូលព្រះអង្គ ﷻ *[១០០:៦] មនុស្សអកតញ្ញូចំពោះព្រះម្ចាស់ខ្លួន?"* អ៊ីម៉ាំ صلوات الله عليه والسلام បានតបថា៖ "មិនមានសទ្ធា ។" ខ្ញុំបានសួរថា៖ "ចុះ *[១០០:៧] ខ្លួនគេផ្ទាល់ជាសាក្សីនៃរឿងនោះ?"* អ៊ីម៉ាំ صلوات الله عليه والسلام បានតបថា៖

"អល់ឡោះហ្ទ៍عَزَّوَجَلَّថែងអំពីបុគ្គលទាំងពីរនាក់នោះ (អាប៊ូ បាការ និង អ៊ូម៉ារ) ដែលបាន ឃើញផ្ទាល់ភ្នែក ច្រក អាល់-យ៉ាប៊ីស ហើយបុគ្គលទាំងពីរនាក់នេះល្មោភជីវិតណាស់ ។"

[قُلْتُ]: قَوْلُهُ: ''أَ فَلاٰ يَعْلَمُ إِذٰا بُعْثِرَ مٰا فِي الْقُبُورِ * وَ حُصِّلَ مٰا فِي الصُّدُورِ * إِنَّ رَبَّهُمْ بِهِمْ يَوْمَئِذٍ لَخَبِيرٌ''؟ قَالَ: «نَزَلَتِ الْآيَتَانِ فِيهِمَا خَاصَّةً، كَانَا يُضْمِرَانِ ضَمِيرَ السَّوْءِ وَ يَعْمَلاَنِ بِهِ، فَأَخْبَرَ اللَّهُ خَبَرَهُمَا وَ فَعَالَهُمَا،

ខ្ញុំបានសួរថា៖ "ព្រះបន្ទូលព្រះអង្គعَزَّوَجَلَّ *[១០០:៩] គេមិនដឹងទេឬ ពេលអ្វីដែលនៅក្នុងផ្នូរត្រូវងើបឡើង [១០០:១០] អ្វីដែលមាននៅក្នុងទ្រូងត្រូវបើកឲ្យឃើញ ? [១០០:១១] ការពិតថ្ងៃនោះព្រះម្ចាស់ពួកគេទ្រង់ញាណពួកគេច្បាស់?*" អ៊ីម៉ាំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមានវចនៈថា៖ "អាយ៉ាស់ទាំងពីរត្រូវដាក់ចុះមកស្ដីអំពីបុគ្គលទាំងពីរនាក់នោះ (អាប៊ូ បាការ និង អ៊ូម៉ារ) ជាពិសេស ។ បុគ្គលទាំងពីរនាក់នេះលាក់ទុកនូវគំនិតអាក្រក់ ហើយបានប្រព្រឹត្តតាមគំនិតអាក្រក់នេះ ។ ដូច្នេះអល់ឡោះហ្ទ៍عَزَّوَجَلَّបានប្រាប់ឲ្យដឹងដំណឹងបុគ្គលទាំងពីរនាក់នេះនិងទង្វើរបស់បុគ្គលទាំងពីរនាក់នេះ ។

فَهَذِهِ قِصَّةُ أَهْلِ وَادِي الْيَابِسِ وَ تَفْسِيرُ الْعَادِيَاتِ».

នេះគឺរឿងរ៉ាវរបស់ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស និងសេចក្ដីអធិប្បាយរបស់ស៊ូរ៉ោះត៍ អាល់-អ៊ាឌីយ៉ាត់ ។" (تفسير القمّي 2: 434)

***

٢- ثم قال عليّ بن إبراهيم أيضا في تفسير ''الْعٰادِيٰاتِ ضَبْحاً'': أَيْ عَدْواً عَلَيْهِمْ فِي اَلضَّبْحِ، ضُبٰاحُ اَلْكِلاٰبِ: صَوْتُهَا، ''فَالْمُورِيٰاتِ قَدْحاً'' كَانَتْ بِلاَدُهُمْ فِيهَا حِجَارَةٌ، فَإِذَا وطئتها سَنَابِكُ اَلْخَيْلِ كَانَتْ تقدح مِنْهَا اَلنَّارُ، ''فَالْمُغِيرٰاتِ صُبْحاً'' أَيْ صَبَّحَهُمْ بِالْغَارَةِ ''فَأَثَرْنَ بِهِ نَقْعاً'' قال: ثَارَتِ اَلْغُبْرَةُ مِنْ رَكْضِ اَلْخَيْلِ ''فَوَسَطْنَ بِهِ جَمْعاً''، قال: تَوَسَّطَ اَلْمُشْرِكِينَ بِجَمْعِهِمْ

2. បន្ទាប់មក អាលី ប៊ិន អ៊ីបរ៉ហ៊ីម (នៅក្នុងតាហ្ស៊ីរគុម្មី) បានថាដូចនេះដែរនៅក្នុងតាហ្សៀររបស់លោក អំពី *[១០០:១] [អញស្បថ]នឹងអាជានេយ្យសឹកដង្ហក់* ពោលគឺ ពួកសត្រូវរបស់ពួកគេដង្ហក់ដូចឆ្កែដង្ហក់ឮសូរឃ្មរៗ ។ *[១០០:២] នឹងការបង្កើតផ្កាភ្លើងដោយប៉ះទង្គិច* នៅក្នុងស្រុកមានក្រួស ពេលណាក្រចកសេះប៉ះទង្គិចលើក្រួសនោះ ពេលនោះវាធ្វើឲ្យមានផ្កាភ្លើង ។ *[១០០:៣] នឹងបណ្ដាអ្នកវាយលុកនាពេលព្រលឹម* ពោលគឺការវាយឆ្មក់នៅពេលព្រឹក ។ *[១០០:៤] ដែលធ្វើឲ្យហុយធូលីក្នុងការវាយលុកនោះ* ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមានវចនៈថា៖ "ធូលីហុយឡើងពីជើងសេះបោល ។" *[១០០:៥] ដែលលុកលុយចូលកណ្ដាលប្រជុំជនក្នុងការវាយលុកនោះ ។"* ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមានវចនៈថា៖ "ពួកគេវាយលុកទៅលើពួកពហុទេពនិយម ។"

''إِنَّ الْإِنْسٰانَ لِرَبِّهِ لَكَنُودٌ'' أَيْ كَفُورٌ، وَ هُمُ اَلَّذِينَ أَمَرُوا وَ أَشَارُوا عَلَى أَمِيرِ اَلْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ) أَنْ يَدَعَ اَلطَّرِيقَ مِمَّا حَسَدُوهُ، وَ كَانَ عَلِيٌّ (عَلَيْهِ السَّلاَمُ) قد أَخَذَ بِهِمْ عَلَى غَيْرِ اَلطَّرِيقِ اَلَّذِي أَخَذَ فِيهِ أَبُو بَكْرٍ وَ عُمَرُ، فَعَلِمُوا أَنَّهُ يَظْفَرُ بِالْقَوْمِ، فَقَالَ عَمْرُو بْنُ اَلْعَاصِ لِأَبِي بَكْرٍ: إِنَّ عَلِيّاً غُلاَمٌ حَدَثٌ لاَ عِلْمَ لَهُ بِالطَّرِيقِ، وَ هَذَا طَرِيقٌ مُسْبِعٌ لاَ يؤمن فيه السباع، فمشيا إليه، و قالا له:يا أَبَا اَلْحَسَنِ، هَذَا اَلطَّرِيقُ اَلَّذِي أَخَذْتَ فِيهِ طَرِيقٌ مُسْبِعٌ، فَلَوْ رَجَعْتَ إِلَى اَلطَّرِيقِ؟ فَقَالَ لَهُمَا أَمِيرُ اَلْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ): «الْزَمَا رِحَالَكُمَا، وَ كُفَّا عَمَّا لاَ

يَعْنِيكُمَا، وَ اسْمَعَا وَ أَطِيعَا، فَإِنِّي أَعْلَمُ بِمَا أَصْنَعُ» فسكتا.

*[១០០:៦] មនុស្សអកតញ្ញូចំពោះព្រះម្ចាស់ខ្លួន* ពោលគឺ បានបដិសេធសទ្ធា ពួកគេគឺពួកដែលបានកត់សំគាល់ថា អាមីរុល-មុមីនីន صلوات الله عليه والسلام បានចាកចេញពីផ្លូវរបស់បុគ្គលទាំងពីរនាក់នោះ ពួកគេច្រណែន ។ អ៊ុាលី صلوات الله عليه والسلام បានយកផ្លូវមួយផ្សេងពីផ្លូវដែល អាប៊ូ បាការ និង អ៊ុម៉ារ បានយក កាលពីមុននោះ ។ ដូច្នេះពួកគេបានដឹងថាព្រះអង្គ صلوات الله عليه والسلام នឹងមានជ័យជំនះលើពួកប្រជារាស្ត្រ ។ អាស្រ័យហេតុនេះ អ៊ុំរ៉ូ ប៊ិន អាល់-អាស្វ៉ បានប្រាប់ អាប៊ូ បាការ ថា៖ "អ៊ុាលី صلوات الله عليه والسلام ជាក្មេង គេ صلوات الله عليه والسلام មិនស្គាល់ផ្លូវទេ ។ ផ្លូវនេះមានគ្រោះថ្នាក់ មិនអាចចៀសផុតពីសត្វតោទេ ។" ដូច្នេះគាត់ក៏បានទៅជួបអ៊ុាលី صلوات الله عليه والسلام ប្រាប់ព្រះអង្គ صلوات الله عليه والسلام ថា៖ "អាប៊ូ អាល់-ហ៊ាសាន់ صلوات الله عليه والسلام អឺយ ផ្លូវដែលលោក صلوات الله عليه والسلام យកនោះមានគ្រោះថ្នាក់ដោយសារសត្វតោ ។ លោកគប្បីត្រឡប់ទៅរកផ្លូវ[ដែលខ្ញុំយក]នោះវិញទៅ ?" អាមីរុល-មុមីនីន صلوات الله عليه والسلام បានប្រាប់បុគ្គលទាំងពីរនាក់នោះថា៖ "អស់លោកការពារអ៊ីវ៉ាន់របស់អស់លោក អស់លោកបិទបាំងបំណងរបស់អស់លោក ។ ខ្ញុំ صلوات الله عليه والسلام ឮ ហើយខ្ញុំ صلوات الله عليه والسلام ប្រតិបត្តិតាម[រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله] ។ ដូច្នេះខ្ញុំ صلوات الله عليه والسلام ដឹងច្បាស់ជាងគេអំពីអ្វីដែលខ្ញុំ صلوات الله عليه والسلام កំពុងធ្វើ ។" បុគ្គលទាំងពីរនាក់នោះស្ងាត់មាត់ ។

و قوله: ''وَ إِنَّهُ عَلىٰ ذٰلِكَ لَشَهِيدٌ'' أَيْ عَلَى اَلْعَدَاوَةِ ''وَ إِنَّهُ لِحُبِّ الْخَيْرِ لَشَدِيدٌ'' يَعْنِي حُبَّ اَلْحَيَاةِ حَيْثُ خافا السباع على أنفسهما. فقال الله عزّ و جلّ: ''أَ فَلاٰ يَعْلَمُ إِذٰا بُعْثِرَ مٰا فِي الْقُبُورِ * وَ حُصِّلَ مٰا فِي الصُّدُورِ'' أي يجمع و يظهر ''إِنَّ رَبَّهُمْ بِهِمْ يَوْمَئِذٍ لَخَبِيرٌ''.
(تفسير القمّيّ اَلْجُزْء: ٢ صَفْحَة : ٤٣٩ ، البرهان في تفسير القرآن اَلْجُزْء : ٥ صَفْحَة : ٧٣٥ حَدِيث ٩٩ /١١٨٤١)**

ព្រះបន្ទូលព្រះអង្គ عَزَّ وَجَلَّ *[១០០:៧] ខ្លួនគេផ្ទាល់ជាសាក្សីនៃរឿងនោះ* ពោលគឺ ភាពជាសត្រូវ ។ *[១០០:៨] ការពិតគេស្រឡាញ់ប្រការល្អខ្លាំងណាស់* ។ មានន័យថាស្រឡាញ់ជីវិត ដូច្នេះហើយបានជាពួកគេខ្លាចតោ ។ ដូច្នេះអល់ឡោះហ៍ عَزَّ وَجَلَّ មានព្រះបន្ទូលថា *[១០០:៩] គេមិនដឹងទេឬ ពេលអ្វីដែលនៅក្នុងផ្នូរត្រូវងើបឡើង [១០០:១០] អ្វីដែលមាននៅក្នុងទ្រូងត្រូវបើកឲ្យឃើញ ?* គឺត្រូវប្រមូលនិងត្រូវបង្ហាញឲ្យឃើញ ។ *[១០០:១១] ការពិតថ្ងៃនោះព្រះម្ចាស់ពួកគេទ្រង់ញាណពួកគេច្បាស់ ។"* (تفسير القمّي 2: 439)

***

٣- وَ عَنِ ابْنِ أُورَمَةَ، عَنْ عَلِيِّ بْنِ حَسَّانَ، عَنْ عَبْدِ الرَّحْمَنِ بْنِ كَثِيرٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِهِ عَزَّ وَ جَلَّ: "إِنَّ الْإِنْسٰانَ لِرَبِّهِ لَكَنُودٌ"، قَالَ: «كَنُودٌ بِوَلاَيَةِ أَمِيرِ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ)».

3. [រាយការណ៍]ពី អ៊ីបនូ អៅរ៉ម៉ាស់ តមកពី អ៊ុាលី ប៊ិន ហ៊ាសាន់ តមកពី អ៊ុាប់ឌុលរ៉ោះហ៊្មាន ប៊ិន កាស៊ៀរ តមកពី អាប៊ូ អ៊ុាប់ឌុលឡោះហ៍ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام មានវចនៈអំពីព្រះបន្ទូលអល់ឡោះហ៍ عَزَّ وَجَلَّ *[១០០:៦] មនុស្សអកតញ្ញូចំពោះព្រះម្ចាស់ខ្លួន* ថា៖ "[ស្តីអំពី]អកតញ្ញូរឿងវីឡាយ៉ាស់របស់អាមីរុល-មុមីនីន صلوات الله عليه والسلام ។" (تأويل الآيات 2: 843/ 4)

***

*٤- وَ رَوَى أَيْضاً عَنْ أَحْمَدَ بْنِ هَوْذَةَ عَنْ إِبْرَاهِيمَ بْنِ إِسْحَاقَ عَنْ عَبْدِ اَللَّهِ بْنِ حَمَّادٍ عَنْ عَمْرِو بْنِ شِمْرٍ عَنْ جَابِرِ بْنِ يَزِيدَ عَنْ أَبِي جَعْفَرٍ عَلَيْهِ السَّلاَمُ قَالَ: سَأَلْتُهُ عَنْ قَوْلِ اَللَّهِ عَزَّ وَ جَلَّ ''وَ اَلْعٰادِيٰاتِ ضَبْحاً''؟ قَالَ رَكْضُ اَلْخَيْلِ فِي قِفَالِهَا

*4. គេបានរាយការណ៍ដែរតមកពី អាស់ម៉ាដ់ ប៊ិន ហៅស្ទាស់ តមកពី អ៊ីបរ៉ហ៊ីម ប៊ិន អ៊ីសហ៊ាក់ តមកពី

អាប់ឌុលឡោះហ្វ៍ ប៊ិន ហ៊ាំម៉ាដ្ តមកពី អាំរ៉ូ ប៊ិន ស៊្មីរ តមកពី យ៉ាប៊ៀរ ប៊ិន យ៉ាស៊ីដ្ តមកពី អាប៊ូ យ៉ាក់ហ្វារ ។ លោក[អ្នកអធិប្បាយ]មានប្រសាសន៍ថាខ្ញុំបានសួរព្រះអង្គអំពីព្រះបន្ទូល អល់ឡោះហ្វ៍ *[១០០:១] [អញស្បថ]នឹងអាជានេយ្យសឹកដង្ហក់?* ព្រះអង្គមានវចនៈថា៖ "ទ័ព សេះបោលពេលច្បាំង ។"

’’فَالْمُورِيَاتِ قَدْحاً‘‘؟ قَالَ: تُورِي وَقْد [قُدِحَ] اَلنَّارِ مِنْ حَوَافِرِهَا

*[១០០:២] នឹងការបង្កើតផ្កាភ្លើងដោយប៉ះទង្គិច?* ព្រះអង្គមានវចនៈថា៖ "ផ្កាភ្លើងបណ្ដាលមកពីក្រចកសេះកងទ័ពដែលប៉ះទង្គិច[នឹងរបស់រឹង] ។

’’فَالْمُغِيرَاتِ صُبْحاً‘‘؟ قَالَ: أَغَارَ عَلِيٌّ عَلَيْهِ السَّلاَمُ عَلَيْهِمْ صَبَاحاً

*[១០០:៣] នឹងបណ្ដាអ្នកវាយលុកនាពេលព្រលឹម?* ព្រះអង្គមានវចនៈថា៖ "អាលីវាយលុកពួកគេពេលព្រឹក ។"

’’فَأَثَرْنَ بِهِ نَقْعاً‘‘؟ قَالَ: أَثَرَ بِهِمْ عَلِيٌّ عَلَيْهِ السَّلاَمُ وَ أَصْحَابُهُ اَلْجِرَاحَاتِ حَتَّى اِسْتَنْقَعُوا فِي دِمَائِهِمْ

*[១០០:៤] ដែលធ្វើឲ្យហុយធូលីក្នុងការវាយលុកនោះ?* ព្រះអង្គមានវចនៈថា៖ "អាលីនិងកនព្រះអង្គបានធ្វើឲ្យពួកគេរបួសខ្លាំង ដល់ថ្នាក់ពួកគេឈាមហូរដាបខ្លួន ។

’’فَوَسَطْنَ بِهِ جَمْعاً‘‘؟ قَالَ: تَوَسَّطَ عَلِيٌّ عَلَيْهِ السَّلاَمُ وَ أَصْحَابُهُ دِيَارَهُمْ

*[១០០:៥] ដែលលុកលុយចូលកណ្ដាលប្រជុំជនក្នុងការវាយលុកនោះ?* ព្រះអង្គមានវចនៈថា៖ "អាលីនិងកនព្រះអង្គវាយបំបែកបំបាក់ផ្ទះពួកគេ ។"

’’إِنَّ اَلْإِنْسَانَ لِرَبِّهِ لَكَنُودٌ‘‘؟ قَالَ: إِنَّ فُلاَناً لِرَبِّهِ لَكَنُودٌ

*[១០០:៦] មនុស្សអកតញ្ញូចំពោះព្រះម្ចាស់ខ្លួន?* ព្រះអង្គមានវចនៈថា៖ "បុគ្គលនេះមួយ (អាប៊ូ បាការ) រមិលគុណព្រះម្ចាស់ខ្លួន ។"

’’وَ إِنَّهُ عَلىٰ ذٰلِكَ لَشَهِيدٌ‘‘؟ قَالَ: إِنَّ اَللَّهَ شَهِيدٌ عَلَيْهِ

*[១០០:៧] ខ្លួនគេផ្ទាល់ជាសាក្សីនៃរឿងនោះ?* ព្រះអង្គមានវចនៈថា៖ "ការពិតអល់ឡោះហ្វ៍ជាសាក្សីនៅលើខ្លួនអ្នកនោះ ។"

’’وَ إِنَّهُ لِحُبِّ اَلْخَيْرِ لَشَدِيدٌ‘‘؟ قَالَ: ذَاكَ أَمِيرُ اَلْمُؤْمِنِينَ عَلَيْهِ السَّلاَمُ. (تأويل الآيات ج١ ص٨١٢)

*[១០០:៨] ការពិតគេស្រឡាញ់ប្រការល្អខ្លាំងណាស់?* ព្រះអង្គមានវចនៈថា៖ "នោះគឺ អាមីរុល-

មុមីនីន صلوات الله عليه والسلام ។" (أويل الآيات 1: 812)

***

*٥- «إِنَّ الْإِنْسانَ لِرَبِّهِ لَكَنُودٌ» رَوَى أَبُو أُمَامَةَ عَنِ اَلنَّبِيِّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ أَنَّهُ قَالَ: أَ تَدْرُونَ مَنِ اَلْكَنُودُ؟ قَالُوا: اَللَّهُ وَ رَسُولُهُ أَعْلَمُ، قَالَ: اَلْكَنُودُ اَلَّذِي يَأْكُلُ وَحْدَهُ وَ يَمْنَعُ رِفْدَهُ وَ يَضْرِبُ عَبْدَهُ. (تفسير نور الثقلين ج٥ ص٦٥٧ ح١٣)

*5. *[១០០:៦] មនុស្សអកតញ្ញូចំពោះព្រះម្ចាស់ខ្លួន* គេបានរាយការណ៍តមកពីព្រះសាស្តា صلى الله عليه وآله ថាព្រះអង្គ صلى الله عليه وآله មានព្រះវចនៈថា៖ "អស់លោកដឹងទេថាអ្នកណាបុគ្គលអកតញ្ញូ (រមិលគុណ) ?" ពួកគេបានទូលថា៖ មានតែអល់ឡោះហ៊្ 'عز وجل និងព្រះសាសនៈទូត صلى الله عليه وآله ព្រះអង្គ عز وجل ទេដែលដឹងជាងគេ ។" ព្រះអង្គ صلى الله عليه وآله មានព្រះវចនៈថា៖ "បុគ្គលអកតញ្ញូគឺបុគ្គលដែលបរិភោគតែឯង គេចវេសឲ្យអ្នកដទៃបរិភោគ វាយបម្រើរបស់ខ្លួន ។" (تفسير نور الثقلين 5: 657/ 13)

## ពាក្យរាយ


-បុគ្គលរមិលគុណអល់ឡោះហ្ទ៍ﷻ (មើល ហ្គា. 5) ។.................................................................... ១៥
-រឿងរ៉ាវរបស់ពួកអ្នកស្រុកច្រក អាល់-យ៉ាប៊ីស [១០០:១-១១] ។.................................................... ១២
-រួចពីជំពាក់បំណុលគេ [១០០] ។.............................................................................................. ៤
-ស្ដីអំពីបុគ្គលទាំងពីរនាក់នោះ [១០០:៩-១០] ។............................................................................ ១២
-ស្ងួត្រឲ្យបាត់ឃ្លាន ឲ្យបាត់ស្រេក ឲ្យបាត់ខ្លាច ឲ្យរួចជំពាក់គេ [១០០] ។ ......................................... ៣


Revision: 13/04/2018, 18/11/2022, 19/11/2022 (verset 3 et 4)